# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៤-០២-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០២០៣/០៨៩ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីន យ៉ាវតឺ** (LIN YAO-TE) ហៅ **លឹម តឺ** សញ្ជាតិដើមចិន កើតនៅក្រុងតៃប៉ិ ប្រទេសចិន | ១៥៧១ |
| ៣១-៣-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១៣១ ស្ដីពីការតែងតាំង លោក **ទ៉ឹក ជូវ** ជា **ឧកញ៉ា** | ១៥៧២ |
| ៣១-៣-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៣០៣/១៣១ ស្ទួន ស្ដីពីការតែងតាំង លោក **ចៅ ស៊ុនលី** ជា **ឧកញ៉ា** | ១៥៧៣ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៣៨ ស្ដីពីការតែងតាំងឯកឧត្ដម **ម៉ក់ វ៉ាន់** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន | ១៥៧៤ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤០ ស្ដីពីការតែងតាំង ឧបាសិកា **ញឹក ម៉ុនថា** ជា **ឧកញ៉ា** | ១៥៧៥ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤១ ស្ដីពីការតែងតាំង លោក **គ្រិត នីហ៊ិន** ជា **ឧកញ៉ា** | ១៥៧៦ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤២ ស្ដីពី :<br>១-ការដកតួនាទី និងភារកិច្ច ឯកឧត្ដម **នួច តារិទ្ធ** ពីអនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា<br>២- តែងតាំងលោកជំទាវ **ជុំ ចំណាន** ជាអនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជំនួស ឯកឧត្ដម **នួច តារិទ្ធ** | ១៥៧៧ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤៣ ស្ដីពី ការធ្វើសមាហរណកម្ម ទៅក្នុងឋានន្តរសក្តិឧត្ដមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៥៧៨ |
| ០៨-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤៤ ស្ដីពី ការធ្វើសមាហរណកម្ម ទៅក្នុងឋានន្តរសក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៥៨១ |
| ១៧-៤-២០០៣ | - ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤៦ ស្ដីពីការដកតួនាទី ភារកិច្ច ឯកឧត្ដម **ឈុន សារ៉េត** ពីអនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងតែងតាំង ឯកឧត្ដម **ស៊ុយ ម៉ុនហេង** ជំនួសវិញ | ១៥៨៣ ក |
| ១៧-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤៧ ស្ដីពីការប្រោសព្រះរាជទាន :<br>១-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ចំពោះឯកឧត្ដម **អ៊ឹម ឈុនលឹម**<br>២- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះឯកឧត្ដម **នូ សាំងខន**<br>៣- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះឯកឧត្ដម **ឌី យ៉ាវ** | ១៥៨៣ ខ |
| ១៧-៤-២០០៣ | -ព្រះរាជក្រឹត្យ នស/រកត/០៤០៣/១៤៨ ស្ដីពីការតែងតាំង លោក **ម៉ៅ រិទ្ធីថា** ជា **ឧកញ៉ា** | ១៥៨៣ គ |

# ខ

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


| | | |
|---|---|---|
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌ | ១៥៨៤ |
| ២៣-៤-២០០៣ | -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៥៨៧ក |
| ០៩-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៥៨៨ |
| ០៩-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៥៨៩ |
| ០៩-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ១៥៩០ |
| ១០-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៥៩១ |
| ១៧-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៥៩២ |
| ១៨-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៩៥ |
| ១៨-៤-២០០៣ | -អនុក្រឹត្យលេខ ៣១៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៩៧ |
| ១៨-៤-២០០៣ | -អនុក្រឹត្យលេខ ៣២០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៥៩៨ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦០០ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៦០២ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦០៣ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦០៤ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦០៥ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៦០៦ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៦០៩ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៦១៣ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៦២៣ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៦២៨ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៦៣២ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦៣៤ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦៣៥ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦៣៦ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦៣៧ |
| ២១-៤-២០០៣ | -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៦៣៩ |

# គ


២១-៤-២០០៣ -អនុក្រឹត្យលេខ ៣៣៧ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៤០

២១-៤-២០០៣ -អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៤១

២១-៤-២០០៣ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៤២

២២-៤-២០០៣ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពីការផ្តល់មេដាយការងារ ១៦៤៤

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពីការផ្តល់មេដាយការងារ ១៦៤៦

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្តីពីការផ្តល់មេដាយការងារ ១៦៤៩

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៥៥

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៤អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៥៦

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៥៧

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្តីពីការផ្តល់មេដាយការងារ ១៦៥៨

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១៦៥៩

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៦០

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៦១

២៣-៤-២០០៣ -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៦២


## ២_ សេចក្តីសំរេច


០៩-៤-២០០៣ - សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរ និងធ្វើអាជីវកម្មលើមនុស្ស ១៦៦៣


## ៣ សារាចរណែនាំ


២៣-៤-២០០៣ - សារាចរណែនាំលេខ ០៤ សរណន ស្តីពីការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១១៧ ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ ២០០៣ ១៦៦៥


# III- ការងារបណ្តាក្រសួង

## ១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៨-៤-២០០៣ -ប្រកាសលេខ ១៩៦ MEF/ ស្តីពីការបោះផ្សាយប័ណ្ណរតនាគារគណនីចរន្តលើកទី ២ និងជាបន្តបន្ទាប់សំរាប់ឆ្នាំ ២០០៣ ១៦៦៧


## ២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


១០-៤-២០០៣ - ប្រកាសលេខ ៣៣៤ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " **ព្រៃពោន** " ទៅជាវិទ្យាល័យ " **ព្រៃពោន** " ស្ថិតនៅក្នុងឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្ត ព្រៃវែង ១៦៧០

២១-៤-២០០៣ - ប្រកាសលេខ ៣៤៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ **អង្គរធំ** ស្ថិតនៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ ខេត្ត សៀមរាប ១៦៧១

# ឃ


២១-៤-២០០៣ - ប្រកាសលេខ ៣៤៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ **សៀមរាប** ស្ថិតនៅក្នុងឃុំគោកចក ស្រុកសៀមរាប ខេត្ត សៀមរាប ១៦៧២

២១-៤-២០០៣ - ប្រកាសលេខ ៣៤៧ អយក.ប្រកស្តីពីការប្តូរឈ្មោះវិទ្យាល័យ"**អង្គរបុរី**"ទៅជាវិទ្យាល័យ**ហ៊ុន សែន** " **អង្គរបុរី** " ស្ថិតនៅក្នុងឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ ១៦៧៣

**៣_ ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា**

២៣-៤-២០០៣ - ប្រកាសលេខ ១៤១ សកបយ ស្តីពីការបង្កើតអង្គភាពអនុវត្តគំរោង សាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជា-កូរ៉េ ១៦៧៤

# ព្រះរាជក្រឹត្យ

នស/រកត/០២០៣/០៨៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ .- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីន យ៉ាវតី** (LIN YAO-TE) ហៅ **លឹម តី** (LIM TE) សញ្ជាតិដើមចិន កើតថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៣៧ នៅក្រុងតៃប៉ិ ប្រទេសចិន ។

មាត្រា២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ** លេខៈ ៦៩ ចល

[illegible]

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១៧១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

## តែងតាំង

លោក **ទ៊ីត ជួរ**

**ជា**

## ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣
**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
លេខៈ ១១៧៤ ច ល **ហត្ថលេខា និង ត្រា**
ដើម្បីចម្លងចែក **ជា ស៊ីម**
៣៤ស.០៣.០៣.១៤១
រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] ឆាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៣០៣/១៣១ ស្តី

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

## តែងតាំង

លោក **ប៉ោ ស៊ុនលី**

**ជា**

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣
ឡក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាបង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និង ត្រា**
**ជា ស៊ីម**

លេខៈ ១១៧ ច ល
ដើម្បីចម្លងចែក
៣/ល-០៣-០៣.១៤
រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៣/១៣៤

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ម៉ក់ ម៉ាន់** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសាឆ្នាំ ២០០៣*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

[illegible].០៣.០៤.១៤៩ លេខ: ១១៩ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ០៣ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៤០៣/១៤០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា )

## តែងតាំង

ឧបាសិកា **ញ៉ឹក ប៊ុនថា**

**ជា**

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និង ត្រា**
**ជា ស៊ីម**

លេខ: ១២០ ច ល
ដើម្បីចម្លងចែក

៣រល-០៣-០៤-១៥១

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាំង តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៤០៣/១៤១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

លោក **គ្រិត នីហ៊ាន**

**ជា**

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៣
ស្តូចព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និង ត្រា**
**ជា ស៊ីម**

លេខៈ ១២១ច ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សាវ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៣/១៨២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដកតួនាទី និង ភារកិច្ច ឯកឧត្តម **នូច ភារិទ្ធ** ពីអនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**មាត្រា ២ :** តែងតាំងលោកជំទាវ **ជុន ចំណាន** ជាអនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជំនួសឯកឧត្តម **នូច ភារិទ្ធ** ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា** លេខៈ ១៨២ ច ល

**ជា ស៊ីម**

ពរល-០៣.០៤.១៥៣

ចំលងចេញពីច្បាប់ដើម សម្រាប់ចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ ...**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៣/១៤៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម **ហោ ណាំហុង** | ឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ២ | ឯកឧត្តម **អ៊ុជ គីមអន** | ឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ៣ | ឯកឧត្តម **អ៊ុង ស៊ាន** | ឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៤ | ឯកឧត្តម **ជាង អេងខួន** | ឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៥ | លោកជំទាវ **យូ អយ** | ឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៦ | លោកជំទាវ **ស៊ុន សារឿន** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៧ | ឯកឧត្តម **ចែម ទីឡា** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៨ | ឯកឧត្តម **ហោ សុធន** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៩ | ឯកឧត្តម **ឡុង ទិសាលោ** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៤ |
| ១០ | ឯកឧត្តម **មាស គីមហេង** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៤ |
| ១១ | ឯកឧត្តម **សៀង ឡាប្រេស្ស** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១២ | ឯកឧត្តម **ស៊ា កុសល** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៣ | ឯកឧត្តម **អ៊ុច បូរិទ្ធ** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៤ | ឯកឧត្តម **រស់ គង់** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៥ | ឯកឧត្តម **ហោ ណាំបូរ៉ា** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៦ | ឯកឧត្តម **ចាន់ លេក្ខា** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៧ | ឯកឧត្តម **ឡុង កែម** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៨ | ឯកឧត្តម **ហួត ផល** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |
| ១៩ | ឯកឧត្តម **ហ៊ុល ផានី** | ឧត្តមមន្ត្រី | ថ្នាក់លេខ ៦ |

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

លេខ: ១២៧ច ល ជា ស៊ីម

នរក.០៣.០៤.១៥៤

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៣/១៤៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ .-

ត្រូវបានធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ | លោក អេង យេង | វរមន្ត្រី | ថ្នាក់លេខ ៤ |
| ២ | លោក ហែម ហេង | វរមន្ត្រី | ថ្នាក់លេខ ៤ |
| ៣ | លោកស្រី ឆួច ផានី | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៤ | លោក សុខ សោភ័ណ | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៥ | លោក សរ សម្បត្តិ | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៦ | លោក សំ ថន | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៧ | លោក អ៊ឹម សុគីរ | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៨ | លោក លន់ គីមឃួន | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ៩ | លោក ថៃ ចណ្ណា | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ១០ | លោក អេាក ទ៉េត | វរមន្ត្រី | ថ្នាក់លេខ ៥ |
| ១១ | លោក ទ៉ាន់ ផល | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១២ | លោក ឆាយ សុខន | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៣ | លោក ជុំ សុន្ទរី | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៤ | លោក កាន់ ផារិទ្ធ | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៥ | លោក ហែម សារឯម | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៦ | លោក ឌុយ រី | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៧ | លោកស្រី ហៃ សុន្ទរិន្ទ | វរមន្ត្រី | ថ្នាក់លេខ ៦ |
| ១៨ | លោក កែវ ឈរា | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ១៩ | លោកស្រី ឆួត បញ្ញា | វរមន្ត្រី | ថ្នាក់លេខ ៧ |
| ២០ | លោកស្រី សឿង រដ្ឋចារី | វរមន្ត្រី | ថ្នាក់លេខ ៨ |
| ២១ | លោក ណៃ ម៉េងអ៊ាង | វរមន្ត្រី | ថ្នាក់លេខ ៨ |

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និង ត្រា
ជា ស៊ីម

នស/រកត-០៣-០៤-១៥៥ លេខ: ១២៤ ចល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៣/១៨៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** ដកតួនាទី និង ភារកិច្ច ឯកឧត្តម ឈុន សារ៉ែត ពីអនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** តែងតាំងឯកឧត្តម ស៊ុយ ម៉ិនហេង ជាអនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជំនួសឯកឧត្តម ឈុន សារ៉ែត ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៣*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

លេខៈ ១២៧ ចល **ហត្ថលេខា និង ត្រា**

ដើម្បីចម្លងចែក

**ជា ស៊ីម**

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស / រកត / ០៤០៣/១៤៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

១-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

-ឯកឧត្តម **អ៊ឹម ឈុនលឹម**

២-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

-ឯកឧត្តម **នូ សាំងខន**

៣-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

-ឯកឧត្តម **ទី យ៉ាង**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣

ត្រូវព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

លេខៈ ១២៧ចំ ល

៣៧៥.០៣.០៤.១៥៨

**ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៤០៣/១៤៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចព្រះសង្ឃរាជព្រះមហាសុមេធាធិបតី )

## តែងតាំង

លោក **ម៉ៅ រិទ្ធីថា**

**ជា**

**ខុកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

លេខៈ ០៤៦៦ច ល

៣រល-០៣-០៤-១៥៣ ...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាអ៊ី គាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើត

## គណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** គណៈកម្មការកម្ពុជា សំរាប់ស្រាវជ្រាវរួមគ្នាជាមួយភាគីថៃ អំពីវិស័យវប្បធម៌ ដើម្បីបើក

វេទិកាសំរាប់ការត្រិះរិះពិចារណារួមគ្នា លើការអប់រំមុខវិជ្ជាប្រវត្តិសាស្ត្រ និងវប្បធម៌ ជាពិសេស លើសៀវភៅសិក្សានៅសាលារៀន ក្នុងគោលបំណងស្ថាបនានូវមនសិការប្រវត្តិ-សាស្ត្រស្របគ្នាមួយ ឈានទៅកាត់បន្ថយអរិភាព និងបង្កើនការយោគយល់គ្នា តាមរយៈការយល់ដឹងត្រឹមត្រូវទៅវិញទៅមក សំរាប់ការពង្រឹង និងអភិវឌ្ឍន៍ទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការយូរអង្វែង រវាងប្រទេសទាំងពីរ ។

**មាត្រា ២ :** គណៈកម្មការខាងភាគីកម្ពុជា មានសមាសភាព ដូចតទៅ :

| | |
|---|---|
| ១-ឯកឧត្តម ស៊ន សំណាង | ប្រធាន |
| ២-ឯកឧត្តម ពិត ចំណាន | អនុប្រធាន |
| ៣-ឯកឧត្តម ស្វាយ ស៊ីថា | អនុប្រធាន |
| ៤-បណ្ឌិត អ៊ីវ ច័ន | អគ្គលេខាធិការ |
| ៥-ឯកឧត្តម នុត ណារ៉ាំង | សមាជិក |
| ៦-ឯកឧត្តម ឡុង សៀម | សមាជិក |
| ៧-ឯកឧត្តម ឆយ យីហ៊ាង | សមាជិក |
| ៨-ឯកឧត្តម រស់ ចន្ទ្រាបុត្រ | សមាជិក |
| ៩-ឯកឧត្តម មីសែល ត្រាណេ | សមាជិក |
| ១០-បណ្ឌិត ព្រុំ ម៉ល់ | សមាជិក |
| ១១-ឯកឧត្តម ពៅ សាមី | សមាជិក |
| ១២-ឯកឧត្តម ស៊ុំ ឈុំប៊ុន | សមាជិក |
| ១៣-លោក យី ធន់ | សមាជិក |
| ១៤-បណ្ឌិត ខៀវ ថារិកា | សមាជិក |
| ១៥-បណ្ឌិត អ៊ុង ជិនណារី | សមាជិក |
| ១៦-លោក ស៊ន សូផាត | សមាជិក |
| ១៧-បណ្ឌិត ឃីង ហុកឌី | សមាជិក |
| ១៨-បណ្ឌិត ផែល ផៅង | សមាជិក |

១៩-បណ្ឌិត ឃីន សុខ សមាជិក
២០-បណ្ឌិត ម៉ក់ ភឹន សមាជិក
២១-ឯកឧត្តម លី គឹមសុខ សមាជិក

មាត្រា ៣ : គណៈកម្មការនេះ ធ្វើការប្រជុំក្រុមឯកទេស ៣ខែម្ដង និង ការប្រជុំរួម ៦ខែម្ដង។ ប្រធានគណៈកម្មការមានភារកិច្ចកោះប្រជុំ ក្នុងករណីចាំបាច់ តាមសំណើរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។ ទីកន្លែង និងកាលបរិច្ឆេទនៃការប្រជុំ នឹងត្រូវកំណត់តាមការឯកភាព ពីភាគីទាំងសងខាង។ អនុសាសន៍នៃការប្រជុំរួមនីមួយៗនឹងត្រូវដាក់ជូនរដ្ឋាភិបាល នៃប្រទេសទាំងពីរសំរាប់ការពិចារណា និងចាត់វិធានការអនុវត្ត តាមលទ្ធភាពជាក់ស្ដែង។

មាត្រា ៤ : គណៈកម្មការខាងភាគីកម្ពុជា ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅរាជបណ្ឌិតសភាកម្ពុជា។

មាត្រា ៥ : ថវិកាសំរាប់ធានាដំណើរការក្នុងលេខាធិការដ្ឋាន និងក្នុងការប្រជុំនានា ដែលរៀបចំនៅក្នុងប្រទេសកម្ពុជា ជាថវិកាជាតិ តាមគំរោងដែលស្នើឡើងដោយគណៈកម្មការ ខាងភាគីកម្ពុជា តាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។

មាត្រា ៦ : គណៈកម្មការនេះមានសិទ្ធិពិនិត្យ ផ្ដល់ការយល់ព្រម និងទទួលជំនួយគ្រប់ផ្នែក ពីប្រភពផ្សេងៗទៀត។

មាត្រា ៧ : គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការឯកទេសផ្សេងៗទៀត តាមការឯកភាព ពីភាគីទាំងសងខាង។

មាត្រា ៨ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៩ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់រាជបណ្ឌិតសភាកម្ពុជា ។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសមាជិកគណៈកម្មការដែលមាននាមចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១០
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១. ចុះថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បកចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកាចំនួន ៥៧០ លានរៀល ( ប្រាំរយចិតសិបលានរៀលគត់ ) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) ជូនក្រសួងទេសចរណ៍ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់បង្គ្រប់ចំណាយលើការរៀបចំវេទិកាទេសចរណ៍អាស៊ាន ( ATF ) និងឆ្នាំទេសចរណ៍កម្ពុជា ២០០៣ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

HONG.DY2 doc

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**    **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣១៣.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានសង្គមកិច្ច និង យុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការ ០២រូប របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម ÷

១- លោក **ដួង ហុង** ជាប្រធាននាយកដ្ឋានសោធននិវត្តន៍ ។

២- លោក **សៀង សុខឃុនឌី** ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

4

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣១៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា១.-** ត្រូវបានតែងតាំងលោក **ជឹង នោមមុនី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យស្ថាបត្យកម្ម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣១៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **មុត ខៀវ** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃក្នុងការចូលរួមចំណែកកសាង និង បំរើប្រទេសជាតិជាពិសេសវិស័យអប់រំ និង ព្រះពុទ្ធសាសនា ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវ ជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

MUX.2.doc

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៧១.[illegible]...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ០២រូប របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម ÷

១- លោក **អ៊ីង សុផុន** ជាអធិការ នៃអគ្គាធិការដ្ឋាន

២- លោក **ង៉ឿង វដ្ឋា** ជាអធិការ នៃអគ្គាធិការដ្ឋាន

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/ ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ នាយទាហាន នាយអាវុធហត្ថ និង នាយនគរបាល និង កងឯកភាពអង្គរក្ស សម្តេច ហ៊ុន សែន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមជូនខាងក្រោម ÷

១- លោកឧត្តមសេនីយ៍ត្រី **នួន ណារិទ្ធ** មេបញ្ជាការរងកងឯកភាពអង្គរក្ស

២- លោកឧត្តមសេនីយ៍ត្រី **គង់ ទណ្ណា** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៣- លោកឧត្តមសេនីយ៍ត្រី **សោម ជន** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៤- លោកឧត្តមសេនីយ៍ត្រី **ម៉ិច សូឌី** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៥- លោកឧត្តមសេនីយ៍ត្រី **អ៊ឹ ម៉ារ៉ា** ជំនួយការឯកឧត្តម **គៀង សាវុធ**

៦- លោកវរសេនីយ៍ឯក **គង់ តារី** នាយសេនាធិការរង កងឯកភាពអង្គរក្ស

| | | |
|---|---|---|
| ៧- លោកវរសេនីយ៍ឯក | ថូ ខេន | នាយសេនាធិការរង កងឯកភាពអង្គរក្ស |
| ៨- លោកវរសេនីយ៍ឯក | ទី សំណាង | ជំនួយការឯកឧត្តម ហ៊ុយ ពិសិដ្ឋ |
| ៩- លោកវរសេនីយ៍ឯក | ខេន សុភា | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១០- លោកវរសេនីយ៍ឯក | ហ៊ួត គឹមសាន្ត | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១១- លោកវរសេនីយ៍ឯក | លឹម ប៊ុនធី | ជំនួយការឯកឧត្តម ហ៊ីង ប៊ុនហៀង |
| ១២- លោកវរសេនីយ៍ឯក | មាស សុខុន | នាយទាហានការពារផ្ទាល់ |
| ១៣- លោកវរសេនីយ៍ឯក | ព្រាប លីណា | នាយទាហានការពារផ្ទាល់ |
| ១៤- លោកវរសេនីយ៍ឯក | ឯល វណ្ណថន | នាយទាហានការពារផ្ទាល់ |
| ១៥- លោកវរសេនីយ៍ឯក | ឈិន សុវណ្ណ | នាយទាហានការពារផ្ទាល់ |
| ១៦- លោកវរសេនីយ៍ឯក | ព្រហ្ម ពន្លឺ | នាយទាហានការពារផ្ទាល់ |
| ១៧ -លោកវរសេនីយ៍ឯក | ម៉ែន ចាន់ | នាយទាហានការពារផ្ទាល់ |
| ១៨- លោកវរសេនីយ៍ឯក | កើត ចន | នាយទាហានការពារផ្ទាល់ |
| ១៩- លោកវរសេនីយ៍ឯក | សំ សារឿន | នាយទាហានការពារផ្ទាល់ |
| ២០- លោកវរសេនីយ៍ឯក | ឡេង គឿន | នាយទាហានការពារផ្ទាល់ |
| ២១- លោកវរសេនីយ៍ឯក | ម៉ម សំ | នាយការិយាល័យអនុព័ន្ធយោធាប្រចាំទីក្រុងបាងកក |
| ២២- លោកវរសេនីយ៍ទោ | យឹម ប៊ុនលី | បញ្ជាការដ្ឋានកងទ័ពជើងទឹក |
| ២៣- លោក | ឆាន់ វឌ្ឍនៈ | អគ្គនាយករង នៃក្រសួងទំនាក់ទំនងរដ្ឋសភា និង អធិការកិច្ច |
| ២៤- លោក | ឯម ស៊ីថា | ប្រធានទីស្នាក់ការគយ និង រដ្ឋាករស្វាទីយ៍រថភ្លើងក្រុងព្រះសីហនុ |
| ២៥- លោក | សុខ ឿន | ព្រះរាជអាជ្ញារង តុលាការក្រុងភ្នំពេញ |
| ២៦- លោក | កែ សាខន | អនុប្រធានទី១ តុលាការក្រុងព្រះសីហនុ |
| ២៧- លោក | គី តិច | ប្រធានគណៈមេធាវី |
| ២៨- លោកវរសេនីយ៍ទោ | ឡៅ ប៊ុនម៉េង | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹកបាត់ដំបង |
| ២៩- លោកវរសេនីយ៍ទោ | អ៊ុក ឃួច | មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹកបាត់ដំបង |
| ៣០- លោកវរសេនីយ៍ទោ | សៅ ចំនួតារា | នាយរងការិយាល័យអនុព័ន្ធយោធាប្រចាំទីក្រុងបាងកក |
| ៣១- លោកវរសេនីយ៍ទោ | យ៉ា ឫទ្ធី | នាយរងការិយាល័យអនុព័ន្ធយោធាប្រចាំទីក្រុងហ្សូជីមិញ |
| ៣២- លោកវរសេនីយ៍ត្រី | ខេង សៅរីបុត្ត | នាយរងការិយាល័យពិធីការ ទំនាក់ទំនងអន្តរជាតិ និង អាស៊ាន |

ស

៣៣- លោកវរសេនីយ៍ទោ **ម៉ម តុលា** នាយទាហានការពារផ្ទាល់

៣៤- លោកវរសេនីយ៍ទោ **ឃួន សាមិត្ត** នាយទាហានការពារផ្ទាល់

៣៥- លោកវរសេនីយ៍ទោ **អ៊ុក សំ** មេបញ្ជាការរង កងអនុសេនាធំ ២៤៦

៣៦- លោកវរសេនីយ៍ទោ **ង៉ាង ចាន់ថុល** នាយលេខាធិការដ្ឋានអង្គរក្ស

៣៧- លោកវរសេនីយ៍ទោ **សំ សំអុល** នាយរងការិយាល័យអភិវឌ្ឍន៍ ក្រាំងចេក

៣៨- លោកវរសេនីយ៍ទោ **អ៊ឹង ពូជធា** ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង**

៣៩- លោកវរសេនីយ៍ទោ **ខ្សែម សុថាវរិទ្ធ** ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង**

៤០- លោកវរសេនីយ៍ត្រី **គន់ អែហៀង** ជំនួយការសន្តិសុខ កងអនុសេនាធំ ១៤៤

៤១- លោកវរសេនីយត្រី **សៀន សារិន** ជំនួយការភស្តុភារ កងអនុសេនាធំ ២៤៦

៤២- លោកវរសេនីយ៍ត្រី **ចាន់ ស្រ៊ុន** នាយរងការិយាល័យទី២

៤៣- លោកវរសេនីយ៍ត្រី **ឡុង គឹមសាន្ត** លេខាឯកឧត្តម **ហ៊ុយ ពិសិដ្ឋ**

៤៤- លោកវរសេនីយ៍ត្រី **ឈុន ពៅ** លេខាឯកឧត្តម **ហ៊ុយ ពិសិដ្ឋ**

៤៥- លោកវរសេនីយ៍ត្រី **អ៊ុក លីឆ្វ** ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣១៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា

## សំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន និងយកអស់កំលាំងកាយចិត្ត ចូលរួមចំណែកក្នុងការកសាង សាលារៀន និង ផ្លូវថ្នល់ នៅក្នុងឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកជំទាវ **ខៀវ ស៊ីណា** | ភរិយាឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ថវិកា | ៥០.០០០ USD |
| ២-លោក **ឆាន ឃិនថុង** | នាយកធនាគារកម្ពុជាសាធារណៈ | ថវិកា | ២០.០០០ USD |
| ៣-លោក **យាំ ស៊ុយសាង** | នាយកធនាគារសហពាណិជ្ជ | ថវិកា | ២០.០០០ USD |
| ៤-លោក **ជា វ៉ាន់ដេរ** | នាយកធនាគារវឌ្ឍនអាស៊ី | ថវិកា | ១៨.០០០ USD |
| ៥-លោក **ពុង ឃាវសែ** | នាយកធនាគារកាណាឌីយ៉ា | ថវិកា | ១៥.០០០ USD |
| ៦-លោក **អែនឌី តាំងស៊ីតុង** | នាយកសាជីវកម្មធនាគារសិង្ហបុរីចំកាត់ | ថវិកា | ១០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **សុក ឈាង** អភិបាលស្រុកបារាយណ៍ (អតីតអភិបាលស្រុកសន្ទុក) ខេត្តកំពង់ធំ
២-លោក **ឈរាំ គា** អភិបាលរងស្រុកសន្ទុក

៣-លោក **អ៊ុន ម៉ុនហាន** ប្រធានការិយាល័យអប់រំ ស្រុកសន្ទុក ខេត្តកំពង់ធំ

៤-លោក **គុង ម៉េងខួន**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសាភិបាលធនាគារជាតិ នៃកម្ពុជា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣១ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **សរ ចំរុង** អភិបាលស្រុកអូរជ្រៅ ដែលបាន បរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងអគារសាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បន្ថែមចំនួន០១ជាន់ ទៀត ចំណាយអស់ទឹកប្រាក់ ចំនួន ២១.៨០០ ដុល្លារអាមេរិក ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ២០រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងអគារទីស្នាក់ការមួយ មាន០៤ខ្នង បំពាក់ដោយគ្រឿងសង្ហារិម ធ្វើសួនច្បារ របងអំពីបេតុង និង បុស្បកព្រះបាទជ័យវរ្ម័នទី៧ នៅច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **អោម ចន្ថា** | ប្រធានច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ | ថវិកា ចំនួន | ១៨.៩៧០ USD |
| ២-លោក | **ឈឹម ប៊ុនធី** | អភិបាលស្រុកម៉ាឡៃ | ថវិកា ចំនួន | ១០.០៥០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ឈាង សេងលី** | ប្រធានទីស្នាក់ការកាំកុងត្រូល | ថវិកា ចំនួន | ៥.០៥០ USD |
| ២-លោក | **សំ ធី** | ប្រធានក្រុមគយ និង រដ្ឋាករ | ថវិកា ចំនួន | ៥.១០០ USD |
| ៣-លោក | **ឈិត លី** | មេបញ្ជាការវរៈការពារព្រំដែនគោក | ថវិកា ចំនួន | ៥.១០០ USD |
| ៤-លោក | **គី គួន** | អភិបាលរងស្រុកម៉ាឡៃ | ថវិកា ចំនួន | ៥.១០០ USD |

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ឃុយ មន** | អភិបាលរងស្រុកម៉ាឡៃ | ថវិកា ចំនួន | ១.០៥០ USD |
| ២-លោក | **ចាយ សារ៉ន** | ប្រធានទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ | ថវិកា ចំនួន | ១.១០០ USD |
| ៣-លោក | **ជួប ធី** | នាយរងក្រុមគយនិងរដ្ឋាករប្រចាំស្រុកម៉ាឡៃ | ថវិកា ចំនួន | ១.០៥០ USD |
| ៤-លោក | **គិះ ទឹម** | មេបញ្ជាការវរៈការពារព្រំដែនល្បាតទី៦ | ថវិកា ចំនួន | ១.០៥០ USD |
| ៥-លោក | **ជុំ វណ្ណៈ** | មេបញ្ជាការរងវរៈការពារព្រំដែនគោក | ថវិកា ចំនួន | ១.០៥០ USD |
| ៦៨ - នាយឯក | ម៉ុំ | យ៉ុម | អត្តលេខ | ២២២៣១០ | បុគ្គលិកពលកម្ម កងស្ពាន |
| ៦៩ - នាយឯក | ជួប | អាម៉ៅ | អត្តលេខ | ២២២១៤៦ | បុគ្គលិកបើកបរ កងថ្នល់ទី ៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧០ | - នាយឯក | ហុច | ហាន | អត្តលេខ | ២២២៣៧០ | បុគ្គលិកពលកម្ម កងស្ពាន |
| ៧១ | - នាយឯក | ញឹម | ញួច | អត្តលេខ | ២២២៣៥៧ | បុគ្គលិកពលកម្ម កងស្ពាន |
| ៧២ | - នាយឯក | ភិន | សារ៉ា | អត្តលេខ | ២២២០៨៤ | បុគ្គលិកពលកម្ម កងថ្មល់ទី ១ |
| ៧៣ | - នាយឯក | ស៊ិន | ឆា | អត្តលេខ | ២២២១៣៥ | បុគ្គលិកពលកម្ម កងស្ពាន |
| ៧៤ | - នាយឯក | សេក | សារ៉ាយ | អត្តលេខ | ២២២១៤៥ | បុគ្គលិកបើកបរ កងថ្មល់ទី ១ |
| ៧៥ | - នាយឯក | ចឹម | សំអឿន | អត្តលេខ | ២២២២២៤ | បុគ្គលិកពលកម្ម កងស្ពាន |
| ៧៦ | - នាយឯក | សេក | សាត | អត្តលេខ | ២២២៤៣៥ | បុគ្គលិកបើកបរ កងថ្មល់ទី ៤ |
| ៧៧ | - នាយឯក | អ៊ូន | អេន | អត្តលេខ | ២២២០៤៦ | បុគ្គលិកបើកបរ កងថ្មល់ទី ១ |
| ៧៨ | - នាយឯក | អ៊ូ | មូល | អត្តលេខ | ២២២៣៣៩ | បុគ្គលិកពលកម្ម កងស្ពាន |
| ៧៩ | - នាយឯក | ចែត | ម៉ាប់ | អត្តលេខ | ២២២០៣៨ | បុគ្គលិកបើកបរ កងថ្មល់ទី ១ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៣៤៣....អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន ០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាង ព្រះវិហារ កំផែងរបង កុដិ បន្ទប់អនាម័យ និង ក្លោងទ្វារ នៅក្នុងវត្តជីនិតារាម ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | **ស៊ិន** | **សោភ័ណ** | ព្រះចៅអធិការវត្ត ជីនិតារាម | បច្ច័យ | ៤៥.១៨០ ដុល្លារ |
| ២-ឯកឧត្តម | **ជា** | **ចាន់តូ** | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ថវិកា | ៦២.២០០ ដុល្លារ |
| ៣-ព្រះតេជគុណ | **អៀម** | **ម៉ីរ** | ព្រះគ្រូសូត្រស្តាំ វត្តជីនិតារាម | បច្ច័យ | ១៥.០០០ ដុល្លារ |
| ៤-ព្រះតេជគុណ | **សោម** | **ជាន** | ព្រះគ្រូសូត្រឆ្វេង វត្តជីនិតារាម | បច្ច័យ | ១១.០០០ ដុល្លារ |
| ៥-លោក | **ឃិន** | **ជុន** | នៅប្រទេសបារាំង | ថវិកា | ២៥.៥០០ ដុល្លារ |
| ៦-លោក | **គីម** | **នី** | នៅសហរដ្ឋអាមេរិក | ថវិកា | ១២.០០០ ដុល្លារ |
| ៧-ឧបាសិកា | **ហេ** | **ឡៃហៀង** | នៅភូមិព្រៃតាត្រាវ ខេត្តកំពង់ធំ | ថវិកា | ១០.៥០០ ដុល្លារ |
| ៨-ឧបាសិកា | **ឃុត** | **តាំងអ៊ិន** | នៅរាជធានីភ្នំពេញ | ថវិកា | ១០.៣០០ ដុល្លារ |
| ៩-ឧបាសក **ហ៊ី ហ៊ឺ** និងឧបាសិកា **ឈុន ឡាង** | | | នៅភូមិព្រៃតាត្រាវ ខេត្តកំពង់ធំ | ថវិកា | ១០.១៥០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៤ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **BRENER-HARRIET-SAM** ដែលបាន ឧបត្ថម្ភជាថវិកា និង សំភារៈជួយកសាងសមិទ្ធផលនានា លើវិស័យអប់រំ និងសង្គមកិច្ច ជាពិសេសជួយ កសាងអគារសិក្សា និង អគារសំរាប់ចិញ្ចឹមទារក រួមចំណែកក្នុងការអភិវឌ្ឍន៍ និង កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ នៅក្នុងស្រុកសំពៅមាស ស្រុកកណ្តៀង និង ស្រុកវាលវែង ខេត្តពោធិសាត់ ចំណាយ អស់ទឹកប្រាក់ សរុបចំនួន ៥៥.២៤១ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តពោធិសាត់ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៤៥ [illegible] - ១៩

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិ សាលាធម្មសភា សាលាបាលី ធម្មចេតិយ៍តម្កល់ព្រះត្រៃបិដក និង សមិទ្ធផលផ្សេងៗទៀត នៅវត្តអូរអណ្តូង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោក **ខៀវ សាអ៊ាត** ថវិកា ៤៥.២០០ ដុល្លារ

២-លោកយាយឧបាសិកា **ឡឹម ទើន** ថវិកា ១៨.១២២ ដុល្លារ

៣-អ្នកស្រី **ជុំ ទ្បៀន** ថវិកា ១៤.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកយាយឧបាសិកា **ទៀន ផាស៊ី** ថវិកា ៩.០០០ ដុល្លារ

២-លោក **ម៉េង សារុន** អ្នកស្រី **លី ហោ** ថវិកា ៨.០០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនឯកឧត្តម **ផាន់ ចាន់ធុល** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ អស់រយៈពេលជាច្រើនឆ្នាំ ព្រមទាំងបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ដើម្បីជួយឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រដែលជួបប្រទះគ្រោះធម្មជាតិនានាកន្លងមក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូន គ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែមេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ំ រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃចំនួន ០៣ អង្គ ដែលបានជួយកសាងព្រះវិហារ កុដិ ក្លោងទ្វារ សាលាវិបស្សនាកម្មដ្ឋាន និង សមិទ្ធផលផ្សេងៗ នៅក្នុងខេត្តមណ្ឌលគិរី ចំណាយអស់បច្ច័យចំនួន ៧២.៧០៧ USD និង ៤២.២០១.០០០ រៀល ដូចមានព្រះនាមខាងក្រោម ÷

| | | |
|---|---|---|
| ១-ព្រះគ្រូមណ្ឌលសោភ័ណ្ឌ | **មេ ខេង** | មេគណខេត្តមណ្ឌលគិរី |
| ២-ព្រះគ្រូមហាធម្មាចារ្យ | **នេព កុសល** | អនុគណស្រុកសែនមនោរម្យ |
| ៣-ព្រះភិក្ខុ | **ម៉ែនស៊ីម សុភាគ** | គ្រូសូត្រឆ្វេងវត្តសែនមនោរម្យ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

AIL1.doc

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៧៤៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**ស ំ រេ ច**

**មាត្រា ១** : ត្រូវបានតែងតាំងលោកវេជ្ជបណ្ឌិត **សុខ ចិន្តា** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកផ្នែកបច្ចេកទេស ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

DARETHAN.3 doc

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៤៩...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ០៣រូប របស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ÷

១- លោក **សៀង ចិន្ត្រា** ជាប្រធាននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស

២- លោក **ទង់ សេងគង់** ជាប្រធាននាយកដ្ឋានរដ្ឋបាល និង កិច្ចការទូទៅ

៣- លោក **អ៊ុន ឃីម** ជាប្រធាននាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ៤ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**សំ រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ហ៊ី សាម៉ន** ជាជំនួយការរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៣៥..ស.សរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីធ្វើវិសោធនកម្មច្បាប់ ស្តីពីការបង្ក្រាបអំពើ ពង្រត់លក់ដូរ និងធ្វើអាជីវកម្មលើមនុស្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីជូនដំណឹងលេខ១១៦៥ សជណ សរ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការយល់ព្រមឱ្យក្រសួងមហាផ្ទៃរៀបចំបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យឡើងវិញច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរ និងធ្វើអាជីវកម្មលើមនុស្ស
- យោងតាមសំណូមពរចាំបាច់

## សំរេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីធ្វើវិសោធនកម្មច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរ និងធ្វើអាជីវកម្មលើមនុស្សដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ប៉ុល លឹម** | ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-លោក | **ឃី ឈិត** | អនុប្រធាននាយកដ្ឋានកិច្ចការព្រហ្មទ័ណ្ឌ និងអនុគ្រោះទោសក្រសួងយុត្តិធម៌ | **អនុប្រធាន** |
| ៣-លោកស្រី | **សម មុន្នីកា** | អគ្គនាយករងកិច្ចការបច្ចេកទេសក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | **សមាជិក** |
| ៤-លោក | **ទូច សាម៉ុន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសង្គមកិច្ចនិងយុវនីតិសម្បទា ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា | **សមាជិក** |
| ៥-ឧត្តមសេនីយ៍ត្រី | **ថោង លឹម** | អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | **សមាជិក** |

៦- ឧត្តមសេនីយ៍ត្រី អ៊ុន សុគន្ធា ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន **សមាជិក**

៧-លោក ជុំ សៀកឌួន ប្រធាននាយកដ្ឋានសុខុមាលភាពសង្គមនៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា **សមាជិក**

៨-លោក ម៉ៅ សុចត្តិ អនុប្រធានទទួលបន្ទុកនាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា **សមាជិក**

៩-លោក គីម សុវណ្ណា ប្រធានការិយាល័យច្បាប់ឯកជន និងអន្តរក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិក**

**ប្រការ២:** ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម :

-ពិនិត្យឡើងវិញនូវភាពចន្លោះប្រហោងនៃច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរនិងធ្វើអាជីវកម្មលើមនុស្ស ទាំងការកំណត់ទ័ណ្ឌកម្ម ការកំណត់ប្រភេទទោស ប្រភេទឧក្រិដ្ឋជន ព្រមទាំងបណ្តានីតិវិធីផ្សេងៗទៀត ដែលត្រូវស្ថិតនៅក្រោមច្បាប់នេះ ។

-ធ្វើកិច្ចពិភាក្សា ដោយសហការជាមួយអង្គការអន្តរជាតិដែលមានការពាក់ព័ន្ធ មន្ត្រីបច្ចេកទេសនៃក្រសួងកិច្ចការអន្តោប្រវេសន៍ ពហុវប្បធម៌ និងជនជាតិដើមរបស់អូស្ត្រាលី ដើម្បីផ្តួចផ្តើម និងកែសំរួលខ្លឹមសារសំរាប់បំពេញបន្ថែមទៅលើភាពចន្លោះប្រហោងនៃច្បាប់នេះ ហើយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០៣

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីស ខេង

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងយុត្តិធម៌

-ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-ដូចប្រការ១

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...០៤...សរ.ណ.ន**

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១១៧ ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ ២០០៣

*****

ទិវាពលកម្មអន្តរជាតិ ១ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមឡើងនាឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និង ជីវភាពរស់នៅ របស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ តាំងពីក្រោយថ្ងៃ ០៧ មករា ១៩៧៩ មកហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលក៏បានកំណត់យកថ្ងៃ ០១ ឧសភា ជាថ្ងៃបុណ្យ ការងាររបស់ពលករ កម្ពុជា និងជាថ្ងៃឈប់សំរាករបស់កម្មករ និយោជិត។ បណ្តាស្ថាប័នរដ្ឋ កម្មករ និយោជិតនៃរោងចក្រ សហគ្រាសជាច្រើនបាន រៀបចំទិវានេះ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព។ ទន្ទឹមនឹងនេះក៏មានក្រុមជនមួយ ចំនួនឆ្លៀតយកទិវា នេះ បង្កការទាមទារផ្សេងៗ រហូតបង្កើតជាអំពើហិង្សា ។

ដើម្បី អោយការប្រារព្ធទិវាពលកម្មអន្តរជាតិ ០១ ឧសភា ខួបលើកទី ១១៧ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងពត៌មាន ម៉ាស៊ីនឃោសនារបស់រដ្ឋត្រូវផ្សព្វផ្សាយ ឱ្យសង្គមជាតិទាំងមូល យល់ពីអត្ថន័យទិវាពលកម្មអន្តរជាតិ ០១ ឧសភា ថាជាសមិទ្ធផលរបស់មនុស្សជាតិ ដែលបានបង្កើតនូវ លក្ខខណ្ឌការងារជាស្តង់ដារ សំរាប់ការអនុវត្តសព្វថ្ងៃនេះ ជាអាទិ៍ ពាក្យស្លោក ៨ ម៉ោងធ្វើការ ៨ ម៉ោងសំរាក ៨ ម៉ោងរៀនសូត្រ ជាដើម។

ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងអនុវត្តលក្ខខណ្ឌការងារ ធានាសិទ្ធិផលប្រយោជន៍កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន១២ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន៦។ ឆ្នាំ ២០០២ កន្លងមកនេះកម្ពុជាបានបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិត ក្រោមបទបញ្ញត្តិនៃច្បាប់ ស្តីពីការងារ ក្នុងគោលបំណងធ្វើអោយលក្ខខណ្ឌការងារ និងជីវភាពរបស់កម្មករ និយោជិតកាន់តែ

ប្រសើរឡើង។ ទន្ទឹមនឹងការពង្រឹងការអនុវត្តច្បាប់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា យើងបាន អនុវត្តគំរោងឃ្លាំមើលលក្ខខណ្ឌការងារឯករាជ្យដែលចាត់ចែងដោយអង្គការអន្តរជាតិ ខាងការងារ (ILO)។ សិទ្ធិសហជីព សិទ្ធិកូដកម្ម ឡុកអៅ ត្រូវបានអនុវត្តយ៉ាងពេញលេញ។ គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាយន្តការត្រីភាគី ត្រូវបានរៀបចំអនុវត្តតួនាទីភារកិច្ចយ៉ាងសកម្ម ។ វិស័យការងារកម្ពុជាកំពុងជាកំលាំងជំរុញថ្មីមួយនៃការ ពង្រីកទីផ្សារនាំចេញផលិតផលទៅអាមេរិក អឺរ៉ុប ដែលបានបង្កើតការងារ ថ្មីជាច្រើនកន្លែង ។

២-ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវណែនាំសហគ្រាស គ្រឹះស្ថានសហការគ្នារៀបចំទិវា ០១ ឧសភា តាមរូបភាពដូចជា :

-ការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថាន ទទួលអំណរទិវា ០១ ឧសភា

-ការជួបជុំជប់លៀង កំសាន្តសប្បាយ ការដើរកំសាន្ត ដើម្បីបង្កបរិយាកាសសាមគ្គីភាព ភាតរភាពនៅតាមសហគ្រាស គ្រឹះស្ថាន។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថជាតិ អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានការណែនាំមន្ត្រី និងកងកំលាំងក្រោមសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបង្កលក្ខណៈងាយស្រួលដល់សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងឱកាសទិវាបុណ្យ ០១ ឧសភា ឆ្នាំ ២០០៣ នេះ ។

រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ ចូលរួមអបអរទិវា ០១ ឧសភា ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព ភាតរភាព ដើម្បីការអភិវឌ្ឍនៃប្រទេសជាតិយើង។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មេសា ឆ្នាំ២០០៣

ហ៊ុន សែន

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង

"ដើម្បីសហការអនុវត្ត"

-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

Nº.១៩៦.....MEF/............

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការបោះផ្សាយប័ណ្ណរតនាគារគណនីចរន្តលើកទី២ និងជាបន្តបន្ទាប់ សំរាប់ឆ្នាំ ២០០៣

*****************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ:០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ នស/រកម /១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ៨៦ សសរ ចុះ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ

- បានឃើញអនុក្រឹត្យលេខ : ០៨ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការដាក់ផ្សាយប័ណ្ណរតនាគារ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ០៨ សសរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- តាមសំណើរបស់ គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ ។

## សំរេច

**ប្រការ ១** : អនុញ្ញាតិអោយរតនាគារជាតិ ចេញផ្សាយលើកទី ២ និង ជាបន្តបន្ទាប់សំរាប់ឆ្នាំ ២០០៣ នូវប័ណ្ណរតនាគារគណនីចរន្តជាប្រាក់រៀល មួយខែម្តង ជារៀងរាល់ខែ មានចំនួនទឹកប្រាក់ ១៦.០០០.០០០.០០០ រៀល ( ដប់ប្រាំមួយពាន់លានរៀល ) ។

**ប្រការ ២** : ប័ណ្ណរតនាគារគណនីចរន្ត ត្រូវបោះផ្សាយដោយរតនាគារជាតិតាមរយៈការដេញថ្លៃបន្តបន្ទាប់ ឬ ផ្សេងពីនេះរហូតដល់កំរិតអតិបរិមាមានទឹកប្រាក់ចំនួន " ៥០ ពាន់លានរៀល " ។

**ប្រការ ៣** : មានតែធនាគារពាណិជ្ជ ឬ អន្តរការីហិរញ្ញវត្ថុប៉ុណ្ណោះ ទើបអាចចុះឈ្មោះជាវប័ណ្ណរតនាគារគណនីចរន្តបាន សំរាប់គណនីរបស់ខ្លួន ឬសំរាប់គណនីរបស់អតិថិជនខ្លួន ។

**ប្រការ ៤** : កាលបរិច្ឆេទនៃការដេញថ្លៃ ទឹកប្រាក់ត្រូវបោះផ្សាយ កាលវសាននិងកាលបរិច្ឆេទត្រូវទូទាត់ប័ណ្ណដែលដេញថ្លៃបាន ត្រូវកំណត់ដោយរតនាគារជាតិ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយគណៈកម្មការចំរុះអន្តរក្រសួង ។

**ប្រការ ៥** : ធនាគារជាតិនៃកម្ពុជា ជាអ្នកទទួលបន្ទុករៀបចំសម័យប្រជុំដេញថ្លៃ ។

**ប្រការ ៦** : បែបបទនៃការដេញថ្លៃ ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា ជាមួយអ្នកមានសិទ្ធចុះឈ្មោះជាវប័ណ្ណ ឬ ជាមួយអ្នកទទួលសិទ្ធប្រទាន ដែលធនាគារជាតិនៃកម្ពុជាទទួលស្គាល់ជាផ្លូវការ ។

**ប្រការ ៧** : លក្ខខ័ណ្ឌនៃការចេញផ្សាយប័ណ្ណរតនាគារ គណនីចរន្តលើកទី ២ និងជាបន្តបន្ទាប់សំរាប់ឆ្នាំ២០០៣ ត្រូវបានកំណត់ដូចតទៅនេះ :

១- ទឹកប្រាក់នៃប័ណ្ណរតនាគារគណនីចរន្តនិមួយ ៗ ត្រូវមានតំលៃស្មើ " ម្ភៃលានរៀល " ( ២០.០០០.០០០ រៀល ) ។

២- អត្រាការប្រាក់ដែលកំណត់ដោយការដេញថ្លៃ គឺជាអត្រាអប្បហាររទូទាត់មុន ។

៣- អាយុកាលនៃប័ណ្ណរតនាគារគណនីចរន្ត គឺ ១៣ សប្តាហ៍ ( ៩១ ថ្ងៃ) ។

៤- ប័ណ្ណរតនាគារត្រូវបានកត់ត្រាបញ្ចូលក្នុងគណនីចរន្តរបស់បរិវិសករ ហើយអាចជួញដូរបានតាមការស្រុះស្រួលព្រមព្រៀងគ្នា ។

៥- តាមរយៈការបង្វែរប័ណ្ណរតនាគារអាចត្រូវបានធ្វើអនុប្បទាន ឬ ដាក់ជាប៉ង់ស្យុង ឬ ដាក់ធានា ។

៦- ប័ណ្ណរតនាគារត្រូវសងវិញនៅថ្ងៃកាលវសាន តាមតំលៃនាមចារឹក

**ប្រការ ៨ :** ធនាគារជាតិនៃកម្ពុជា ទទួលភារៈគ្រប់គ្រងគណនីចរន្តប័ណ្ណរតនាគារ និង ជាពិសេសចាត់ចែងកិច្ចដំណើរការនៃប្រតិបត្តិការនិមួយៗ ដែលពាក់ព័ន្ធទៅនឹងគណនីចរន្តទាំងនោះ ។

**ប្រការ ៩ :** បែបបទនៃកិច្ចដំណើរការគណនីចរន្ត ត្រូវបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងម្ចាស់គណនីចរន្ត ។

**ប្រការ១០:** គណៈកម្មការចំរុះអន្តរក្រសួងរៀបចំបោះផ្សាយប័ណ្ណរតនាគារ រតនាគារជាតិមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាព្រឹទ្ធសភា
- អគ្គលេខារដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- ធនាគារជាតិ នៃកម្ពុជា
- រតនាគារជាតិ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**
លេខ ៣៣៤ អយក.ប្រក

# ប្រ កា ស

ស្តីពីការពង្រីកអនុវិទ្យាល័យ « ព្រៃពោន » ទៅជាវិទ្យាល័យ « ព្រៃពោន »
ស្ថិតនៅក្នុងឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំព្រៃពោន ស្រុកកំពង់ត្របែក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តព្រៃវែង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ម្រេ ច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ព្រៃពោន » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ព្រៃពោន » ស្ថិតនៅក្នុងឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តព្រៃវែង "ដើម្បីជាពត៌មាន
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឆា. មចទ

C:\New school\Takev.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៣៤៧ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ អង្គរធំ ស្ថិតនៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកអង្គរធំ លេខ០៣៧ អយកស្រ.អធ ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា: អនុវិទ្យាល័យ « អង្គរធំ » ស្ថិតនៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តសៀមរាប " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

ភ្នំពេញ , ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ [illegible] អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ សៀមរាប

## ស្ថិតនៅក្នុងឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកសៀមរាប លេខ០៤៧ អយក.ស្រសរ ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តសៀមរាប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « សៀមរាប » ស្ថិតនៅក្នុងឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តសៀមរាប " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ...៣៤៧.........អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ « អង្គរបុរី »ទៅជាវិទ្យាល័យ ហ៊ុន សែន « អង្គរបុរី »
ក្នុងឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ ។

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២ ។
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំអង្គរបុរី ស្រុកអង្គរបុរី ចុះថ្ងៃទី ០១ ខែ មករា ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ « អង្គរបុរី »បច្ចុប្បន្ន ទៅជាវិទ្យាល័យ ហ៊ុន សែន « អង្គរបុរី » ស្ថិតនៅក្នុងឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និង នាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " <u>ដើម្បីជ្រាបជាពត៌មាន</u> "
- សាលាខេត្តតាកែវ " <u>ដើម្បីជាពត៌មាន</u> "
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Open and rename.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ១៤១ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពី

## ការបង្កើតអង្គភាពអនុវត្តគំរោង សាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជា-កូរ៉េ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- យោងកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអាហារ័ណ នីហារ័ណ នៃសាធារណៈរដ្ឋកូរ៉េ លេខ KHM-2 ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០២
- ពិនិត្យឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-** បង្កើតអង្គភាពមួយមានឈ្មោះថា **អង្គភាពអនុវត្តគំរោង** ដើម្បីដឹកនាំ និងគ្រប់គ្រងដំណើរការកសាងសាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា-កូរ៉េ ដែលមានរចនាសម្ព័ន្ធ និងសមាសភាពដូចតទៅ :

### ក. គណៈកម្មការដឹកនាំ

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាប្រធានអង្គភាព |
| ២- ឯកឧត្តម **អ៊ុំ មាន** | អគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជានាយកគំរោង |
| ៣- លោក **ឃួន វ៉ាន់ឌីន** | អគ្គនាយករងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | ជាអ្នកចាត់ចែងគំរោង |
| ៤- លោក **សួស យ៉ារ៉ា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាទីប្រឹក្សាអមគំរោង |

**ខ. ផ្នែកជំនួយការ**

**- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ១- លោក **ហ៊ូ ទុន្នី** | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាប្រធាន |
| ២- លោក **ញៀម ចាន់ណេ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | ជាអនុប្រធាន |
| ៣-លោក **កេត ឡឿន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៤- លោក **នួន សារួន** | អនុប្រធានការិយាល័យពតិមាន | ជាសមាជិក |

**- ផ្នែកគ្រប់គ្រងសាលា និងអភិវឌ្ឍន៍ធនធានមនុស្ស**

| | | |
|---|---|---|
| ១- លោក **ម៉ែន សុមិត្រ** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាប្រធាន |
| ២- លោក **ផង់ ថាវេត** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាអនុប្រធាន |
| ៣- លោក **ហ៊ុយ ឫទ្ធិរង្សី** | អនុប្រធានការិយាល័យអប់រំ | ជាសមាជិក |
| ៤- លោក **ញ៉ឹក ផល្លី** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ៥- លោក **គុណា ដាស៊ីន** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ៦- កញ្ញា **យុក គីមលាង** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |

**- ផ្នែកបច្ចេកទេស**

| | | |
|---|---|---|
| ១- លោក **មាស រ៉ាមី** | នាយករងមជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ កម្ពុជា-ថៃ | ជាសមាជិក |
| ២- លោក **ឆិត ផេង** | អនុប្រធានការិយាល័យលទ្ធកម្ម | ជាសមាជិក |

**ប្រការ ២.-** គណៈកម្មការដឹកនាំ និងផ្នែកជំនួយការមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោមនេះ :

ក- ប្រធានអង្គភាព ជាអ្នកទទួលខុសត្រូវរួម ។

ខ- នាយកគំរោង ជាអ្នកទទួលខុសត្រូវក្នុងការដឹកនាំដំណើរការអនុវត្តន៍គំរោង ។

គ- អ្នកចាត់ចែងគំរោង ជាជំនួយការឱ្យនាយកគំរោងក្នុងការចាត់ចែងដំណើរការអនុវត្តន៍គំរោង ។

ឃ-ទីប្រឹក្សាអមគំរោង ជាអ្នកចូលរួមផ្តល់យោបល់ និងសំរបសំរួលជាមួយមជ្ឈដ្ឋានពាក់ព័ន្ធ ក្នុងការគ្រប់គ្រង ចាត់ចែងដំណើរការអនុវត្តន៍គំរោង ។

ង- ផ្នែកជំនួយការ ជាសេនាធិការសំរួលរាល់កិច្ចការប្រចាំថ្ងៃរបស់គណៈកម្មការដឹកនាំ ។

**ប្រការ ៣.-អង្គភាពអនុវត្តគំរោង** មានភារកិច្ច :

- រៀបចំកសាង និងគ្រប់គ្រងចាត់ចែងឯកសារគ្រប់ប្រភេទដែលពាក់ព័ន្ធ ដើម្បីបំពេញសំណូមពរគោលការណ៍ និងនីតិវិធីទាំងកិច្ចការផ្លូវច្បាប់ និងហិរញ្ញកិច្ច ។

- ដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធ តាំងពីជំហានចាប់ផ្តើមរហូតដល់បញ្ចប់ការដ្ឋាន ដោយឈរលើមូលដ្ឋានសំរបសំរួលជាមួយប្រជាជន ក៏ដូចជាអាជ្ញាធរគ្រប់ជាន់ថ្នាក់ ដើម្បីធានាសុវត្ថិភាព និងប្រសិទ្ធិភាពការងារ ។
- សហការជាមួយអ្នកពិគ្រោះយោបល់(Consultant) កូរ៉េ ក្នុងការតាមដាន ត្រួតពិនិត្យការងារបច្ចេកទេស គុណភាព សំភារៈបរិក្ខា ដែលសំរាប់ធ្វើការសាងសង់ និងបំពាក់ ផ្អែកតាមគោលការណ៍ និងបទដ្ឋាននៃគំរោងដែលបានឯកភាព និងស្របតាមការណែនាំរបស់ធនាគារ (Import-Export Bank of Korea) ។
- សហការជាមួយជំនាញការ (Experts) កូរ៉េ ក្នុងការបង្កើតឡើងនូវកម្មវិធីបណ្តុះបណ្តាល ថ្នាក់ជាតិ កសាងសៀវភៅសិក្សា កម្មវិធីបំពាក់បំប៉នគ្រូ និងគ្រប់គ្រងសាលា ដោយយោងតាមប្រការដែលបានឯកភាពគ្នា ។
- ជួយសំរួលកិច្ចការរដ្ឋបាលក្នុងស្រុកជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តគំរោងឱ្យបានជោគជ័យ ។

**ប្រការ ៤.-** គណៈកម្មការដឹកនាំត្រូវចាត់ចែងប្រជុំសាមញ្ញ២ ដងក្នុងមួយខែ ។ ក្នុងករណីចាំបាច់ ឬយោងតាមសំណូមពររបស់ប្រធានអង្គភាព ឬសមាជិកណាម្នាក់នៃគណៈកម្មការដឹកនាំ អង្គប្រជុំវិសាមញ្ញត្រូវរៀបចំដំណើរការ ។ ពេលអវត្តមាន ឬមានការចាំបាច់ ប្រធានអង្គភាពអាចប្រគល់ការដឹកនាំអង្គប្រជុំជំនួសដោយនាយកគំរោង ។

**ប្រការ ៥.-** ឯកឧត្តម អស់លោក និងនាងកញ្ញា ដូចមានរាយនាមក្នុងប្រការ ១ និងអង្គភាពពាក់ព័ន្ធទាំងអស់ ដែលស្ថិតក្រោមឱវាទក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវអនុវត្តរាល់ប្រការនៃប្រកាសនេះប្រកបដោយស្រិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**<u>ចំលងជូន:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាក្រុងភ្នំពេញ
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៥ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ